វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជនបទកម្ពុជា
CIRD
Cambodian Institute for Research and Rural Development

HelpAge International
age helps

Funded by
age UK
Improving the lives of older people

# បច្ចេកទេសសាមញ្ញក្នុងការចិញ្ចឹមមាន់ដើម្បីបានផលខ្ពស់



## ឯកសារសំរាប់ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ

រៀបរៀងដោយៈ បណ្ឌិត មាឃ ប្រមូល / Dr. Meak Pramol

ខែ កុម្ភៈ ឆ្នាំ ២០១១

# បុព្វកថា

ឯកសារដែលអស់លោក អ្នក កំពុងអាននេះគឺជាសេចក្តីណែនាំអំពីលំដាប់លំដោយបច្ចេកទេសក្នុងការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារនៅក្នុងលក្ខខណ្ឌនៃប្រទេសកម្ពុជា។ ឯកសារនេះផលិតឡើងសម្រាប់ជាជំនួយស្មារតីដល់កសិករឈានមុខ និង អ្នកផ្សព្វផ្សាយបច្ចេកទេសនៅតាមមូលដ្ឋានជនបទ ដោយអ្នកនិពន្ធព្យាយាមប្រើប្រាស់ពាក្យពេចន៍សាមញ្ញៗ និង លើកឡើងនូវបច្ចេកទេសងាយៗតែមានសារៈសំខាន់ និង ដែលអាចយកមកអនុវត្តបាននៅក្នុងលក្ខខណ្ឌជនបទនៃប្រទេសកម្ពុជា។ ខ្លឹមសារដែលបានលើកយកមកបង្ហាញនៅទីនេះ គឺទាញចេញពីបទពិសោធន៍ជាក់ស្តែងដែលអ្នកនិពន្ធទទួលបានតាមរយៈការពិសោធន៍ស្រាវជ្រាវជាមួយកសិករនៅតាមកសិដ្ឋានរបស់ពួកគាត់នៅតាមទីកន្លែងជាច្រើននៅក្នុងប្រទេសកម្ពុជា។

ឯកសារនេះជាចំណែកមួយក្នុងចំណោមឯកសារបច្ចេកទេសកសិកម្មផ្សេងៗទៀតដែលបានបោះពុម្ពផ្សាយដោយ **វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជនបទកម្ពុជា** (**អង្គការ សៀដ** - CIRD) ដើម្បីជាការចែករំលែកផ្សព្វផ្សាយនូវចំណេះដឹង និង បទពិសោធន៏អំពីបច្ចេកទេសផលិតកម្មកសិកម្មដល់កសិករនៅតាមជនបទដែលតែងព្យាយាមរិះរកគ្រប់មធ្យោបាយដើម្បីបង្កើនទិន្នផលកសិកម្មរបស់ខ្លួន។ **អង្គការ សៀដ** (CIRD) សូមថ្លែងអំណរគុណចំពោះអង្គការ HelpAge International ដែលបានឧបត្ថម្ភថវិកាសម្រាប់ការបោះពុម្ព។

យើងខ្ញុំយល់ឃើញថាខ្លឹមសារនៃសៀវភៅនេះពិតជានៅមានចំនុចខ្វះខាត ដូចនេះយើងខ្ញុំរីករាយនឹងទទួលនូវមតិយោបល់ ឬចំណាប់អារម្មណ៏ផ្សេងៗសំរាប់កែលំអពីសំណាក់អស់លោក-អ្នកដែនបានអាន ក៏ដូចជាពីសំណាក់ បង ប្អូន ពូ មីង ជាកសិករដែលបានអនុវត្ត ផ្សព្វផ្សាយ និងតាមដាននូវបច្ចេកទេសដែលណែនាំទាំងនេះ។

**ប្រាក់ សេរីវឌ្ឍន៏**

**នាយកអង្គការសៀដ - CIRD**

# មាតិកាអត្ថបទ

ទំព័រ


I. ចំណេះដឹងមូលដ្ឋានសំរាប់ចិញ្ចឹមមាន់ឱ្យបានផលខ្ពស់ ១

១. ពូជមាន់សំខាន់ៗនៅក្នុងប្រទេសកម្ពុជា ១

១.១. ពូជមាន់ក្នុងស្រុក ១

១.២. ពូជមាន់នាំចូល ១

២. ចំណីអាហារសំរាប់មាន់ ២

២.១. ប្រភេទអាហារ ថាមពល ឬ អាហារទ្រទ្រង់ ២

២.២. ប្រភេទអាហារ ប្រូតេអ៊ីន ឬ អាហារជាតិសាច់ ៣

២.៣. ប្រភេទអាហារ វីតាមីន ឬ អាហារការពារ ៣

២.៤. ប្រភេទអាហារ ជាតិរ៉ែ ៤

២.៥. ចំណីលក់លើទីផ្សារ ៤

២.៦. ចំណីបន្ថែម ៥

៣. របៀបលាយចំណី ៦

៤. ទឹក ៧

៥. ការលូតលាស់របស់មាន់ ៧

II. បច្ចេកទេសសាមញ្ញក្នុងការចិញ្ចឹមមាន់ឱ្យលូតលាស់បានល្អ ៧

១. ការជ្រើសរើស និងបង្កាត់ពូជ ៨

១.១. របៀបជ្រើសរើសបា ៨

១.២. របៀបជ្រើសរើសមេ ៩

២. ការរៀបចំជំរកសមស្របសំរាប់មាន់ ៩

៣. ការកំណត់ទីធ្លាសំរាប់មាន់ដើររកចំណី ១០

៤. ការរៀបចំទ្រុងសំរាប់ចិញ្ចឹមមាន់ ១០
៥. ការផ្តល់ទឹកស្អាតឱ្យមាន់ផឹក ១០
៦. ការដាក់ចំណីឱ្យមាន់ស៊ី ១០
៧. ការប្រើប្រាស់ឱសថបុរាណដើម្បីការពារជំងឺមាន់ ១១
៨. ការការពារស្រមើលនៅលើសំបុកមាន់ ១១
៩. ការការពារកូនមាន់កុំឱ្យមាន់ផ្សេងទៀតចឹក និងជាន់ ១២
១០. ការទំលាក់ព្រូនមាន់ ១៣
១១. ការធ្វើអនាម័យ និងវិធានការណ៍បង្ការជំងឺផ្សេងៗ ១៣

III. ជំងឺមាន់ដែលជួបប្រទះក្នុងការចិញ្ចឹម និងការព្យាបាល ១៤

១. ជំងឺញូវកាស (Newcastle Diseases) ១៤
២. អាសន្នរោគបក្សី (Fowl Cholera) ១៦
៣. ជំងឺអុតបក្សី (Fowl Pox) ១៨
៤. ជំងឺរាកបក្សី ( Pullorum Diseases ) ២០
៥. ជំងឺកុកស៊ីដ្យូស៊ីស (Coccidiosis) ២២

IV. របៀបប្រើវ៉ាក់សាំងការពារជំងឺមាន់ ២៣

១. វ៉ាក់សាំងញូវកាស អេហ្វ F ( ប្រភពពីប្រទេសវៀតណាម) ២៣
២. វ៉ាក់សាំងញូវកាស ឡាសូតា ( ប្រភពពីប្រទេសវៀតណាម) ២៣
៣. វ៉ាក់សាំងញូវកាស អឹម M ( ប្រភពពីប្រទេសវៀតណាម) ២៤
៤. វ៉ាក់សាំងអាសន្នរោគបក្សី ( ប្រភពពីប្រទេសវៀតណាម) ២៥
៥. វ៉ាក់សាំងអាសន្នរោគបក្សី ( ប្រភពពីប្រទេសថៃ) ២៦
៦. វ៉ាក់សាំងការពារជំងឺអុតមាន់ ( ប្រភពពីប្រទេសវៀតណាម) ២៦
៧. វ៉ាក់សាំងការពារជំងឺអុតមាន់ ( ប្រភពពីប្រទេសថៃ) ២៧

# តារាង

**តារាងទី ១:** វ៉ាក់សាំងការពារជំងឺ ញ៉ូវកាស ១៦

**តារាងទី ២:** វ៉ាក់សាំងការពារជំងឺ អាសន្នរោគបក្សី ១៧

**តារាងទី ៣:** វ៉ាក់សាំងការពារជំងឺ អុតបក្សី ២០

# រូបភាព

**រូបភាពទី ១:** ពូជមាន់ក្នុងស្រុក ១

**រូបភាពទី ២:** ពូជមាន់នាំចូល ២

**រូបភាពទី ៣:** ចំណីផ្តល់ថាមពល ២

**រូបភាពទី ៤:** ចំណីផ្តល់ប្រូតេអ៊ីន ៣

**រូបភាពទី ៥:** ចំណីផ្តល់ វីតាមីន ៣

**រូបភាពទី ៦:** ចំណីផ្តល់ សារធាតុរ៉ែ ៤

**រូបភាពទី ៧:** ព្រីម៉ិច លក់លើទីផ្សារ ៥

**រូបភាពទី ៨:** ទ្រុងសំរាប់កូនមាន់ ១២

**រូបភាពទី ៩:** ការផ្តល់ចំណីមាន់ និងការការពារជំងឺ ១៤

# ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ

## I. ចំណេះដឹងមូលដ្ឋានសំរាប់ចិញ្ចឹមមាន់ឱ្យបានផលខ្ពស់

### ១. ពូជមាន់សំខាន់ៗនៅក្នុងប្រទេសកម្ពុជា

#### ១.១. ពូជមាន់ក្នុងស្រុក

លក្ខណៈសំគាល់របស់ពូជមាន់ក្នុងស្រុក គឺមានខ្លួនតូច លូតលាស់យឺត ពងតិច ប៉ុន្តែធន់ទៅនឹងជំងឺជាងពូជមាន់នាំចូល។ ពូជមាន់ក្នុងស្រុក មានលក្ខណៈពិសេសងាយបន្សាំទៅនឹងអាកាសធាតុ ស៊ីចំណីមិនរើស អាចលែងឱ្យដើររកស៊ីទៅតាមភូមិ ចេះថែរក្សាកូន និងអាចក្រាបភ្ញាស់កូនបានដោយខ្លួនឯង។ ពូជមាន់ក្នុងស្រុកសំខាន់ៗរួមមាន មាន់សំពៅ មាន់ស្គួយ មាន់ចែ មាន់ក្លឹង មាន់សំឡី មាន់ក្រញាស់ មាន់ប្រជល់ និងមាន់កណ្តូង... ។ល។



រូបទី ១: ពូជមាន់ក្នុងស្រុក

#### ១.២. ពូជមាន់នាំចូល

គឺជាពូជនាំចូលពីបរទេស ពូជនេះភាគច្រើនត្រូវបានគេធ្វើការបង្កាត់ និងជ្រើសរើសយ៉ាងសិរិតសំរាំងដើម្បីឱ្យវាផ្តល់ទិន្នផលខ្ពស់ ហើយភាគច្រើនត្រូវបានគេចិញ្ចឹមជាលក្ខណៈទ្រង់ទ្រាយធំ។ ពូជមាន់នាំចូលគេសង្កេតឃើញមាន ២ ប្រភេទ គឺពូជសំរាប់ចិញ្ចឹមយកសាច់ និងពូជសំរាប់ចិញ្ចឹមយកពង។ ការ